# សេចក្តីប្រកាសព័ត៌មាន

## អង្គការមិនមែនរដ្ឋាភិបាលសាទរ ចំពោះគម្រោងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្កើនការផលិតថាមពលអគ្គិសនីពីពន្លឺព្រះអាទិត្យឲ្យបាន២០%

អង្គការមិនមែនរដ្ឋាភិបាល ធ្វើការលើវិស័យអភិបាលកិច្ចទឹកនៅកម្ពុជា សូមសំដែងការអបអរសាទរ ដែលកាលពីពេលថ្មីៗនេះ[1]រដ្ឋាភិបាលកម្ពុជា បានប្រកាសពីការបង្កើននូវបរិមាណផលិតថាមពលពីពន្លឺព្រះអាទិត្យឲ្យបាន២០% នៃផែនការថាមពលជាតិសរុប នៅឆ្នាំ២០២៣ និងបានអះអាងពីការមិនចង់ឃើញការសាងសង់ទំនប់វារីអគ្គិសនីនៅលើទន្លេមេគង្គឡើយ។

ការបង្កើនការផលិតថាមពលពីពន្លឺព្រះអាទិត្យឲ្យបានច្រើនក្នុងរយៈពេលខ្លី ជារឿងដែលគួរឲ្យសាទរ និងរីករាយបំផុតនៅក្នុងតំបន់ ខណៈកម្ពុជាគិតត្រឹមឆ្នាំ២០១៨ បរិមាណដែលផលិតថាមពលពីពន្លឺព្រះអាទិត្យនេះមានត្រឹមតិចជាង១%[2]ប៉ុណ្ណោះ។ លោកស្រី Courtney Weatherby អ្នកស្រាវជ្រាវនៅវិទ្យាស្ថាន Stimson យល់ស្របថាការកំណត់គោលដៅនេះអាចទៅរួចដោយសារថ្មីៗនេះៗ រដ្ឋាភិបាលកម្ពុជា បានអនុម័តបន្ថែមនូវគម្រោងផលិតថាមពលពន្លឺព្រះអាទិត្យប្រមាណជាង ១០០ មេហ្គាវ៉ាត់។ លោកស្រី បានលើកឡើងថា *«បន្ថែមជាមួយថាមពលពន្លឺព្រះអាទិត្យ ១០មេហ្គាវ៉ាត់នៅស្ថានីយ៍ដែលមានស្រាប់នៅស្វាយរៀង និងប្រមាណ៨០មេហ្គាវ៉ាត់នៅកំពង់ស្ពឺ និងផែនការសាងសង់១២០មេហ្គាវ៉ាត់នៅកំពង់ឆ្នាំង និងពោធិ៍សាត់ ដែលបានអនុម័តរួចហើយ ខ្ញុំយល់ថា គោលដៅឆ្នាំ២០២៣ អាចទៅរួច»*។

ការសម្រេចចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជាបែបនេះ ស្របនឹងរបកគំហើញនៃការសិក្សាស្រាវជ្រាវរបស់គណៈកម្មការទន្លេមេគង្គ[3]ស្តីពីការគ្រប់គ្រង និងអភិវឌ្ឍន៍អាងទន្លេមេគង្គប្រកបដោយចីរភាពក្នុងឆ្នាំ២០១៧ ដែលបានផ្តល់អនុសាសន៍ដល់ប្រទេសជាសមាជិក គួរបង្វែរការយកចិត្តទុកដាក់ទៅលើថាមពលស្អាត ដើម្បីកាត់បន្ថយការពឹងផ្អែកខ្លាំងទៅលើទំនប់វារីអគ្គិសនី។ ជាមួយគ្នានេះដែរ ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩-២០២៣ រដ្ឋាភិបាលកម្ពុជាបានដាក់ចេញការបង្កើតក្របខណ្ឌគោលនយោបាយ ច្បាប់ ស្តីពីការលើកកម្ពស់ការផលិតថាមពលស្អាត និងថាមពលកកើតឡើងវិញ ដែលជាការចូលរួមចំណែកជាសកល ក្នុងការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីកាត់បន្ថយការប្រែប្រួលអាកាសធាតុឲ្យបាន១៦% ក្នុងវិស័យថាមពលនៅឆ្នាំ២០៣០។ ម្យ៉ាងវិញទៀត

---

[1] https://www.phnompenhpost.com/business/govt-reduce-reliance-hydro

[2] EAC Consolidation report 2018

[3] http://www.mrcmekong.org/assets/Publications/Council-Study/Council-study-Reports-discipline/Council-Study-BioRA-Final-Technical-Report-VOLUME-4-Development-Scenarios-FINAL-REPORT-DEC-2017.pdf

ផែនការដដែលនេះ ក៏បានថែងអំពីការអភិវឌ្ឍប្រកបដោយចីរភាពនៃអាងទន្លេមេគង្គ[4] និងរួមចំណែកដល់ការសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ជាពិសេសគោលដៅទី៦ "**ធានាឲ្យបាននូវធនធានទឹក និងការគ្រប់គ្រងប្រកបដោយចីរភាព និងអនាម័យសម្រាប់ទាំងអស់គ្នា**"។

នាយកប្រតិបត្តិវេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា និងជាតំណាងអង្គការសង្គមស៊ីវិល ដែលធ្វើការងារទាក់ទងនឹងអភិបាលកិច្ចទឹក លោកបណ្ឌិត តឹក វណ្ណារ៉ា បានសំដែងការអបអរសាទរចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានដាក់ចេញនូវផែនការជាក់លាក់ក្នុងការផលិតមពលពីពន្លឺព្រះអាទិត្យឲ្យបានច្រើនជាអតិបរមា ជាពិសេសការអះអាងពីការមិនចង់ឃើញទំនប់វារីអគ្គិសនីត្រូវបានសាងសង់នៅតួទន្លេមេគង្គឡើយ។ លោកបន្ថែមថា *«ខ្ញុំយល់ថាការដាក់ចេញនូវផែនការទាំងនេះ គឺបានឆ្លើយតបទៅនឹងអនុសាសន៍របស់គណៈកម្មការទន្លេមេគង្គ តាមរយៈការសិក្សា Council Study ដែលបានផ្តល់អនុសាសន៍ឲ្យប្រទេសជាសមាជិក ត្រូវគិតគូរលើការផលិតថាមពលពីបច្ចេកវិទ្យាថ្មីៗ ដូចជាពីថាមពលខ្យល់ និងព្រះអាទិត្យ ដែលមានសក្តានុពលក្នុងតំបន់ ដើម្បីកាត់បន្ថយការពឹងផ្អែកទៅលើទំនប់វារីអគ្គីសនី»*។

ប្រទេសនៅក្នុងតំបន់រួមទាំងកម្ពុជា បានជួបប្រទះនូវបាតុភូតនៃភាពរាំងស្ងួតនាដើមឆ្នាំ ២០១៩ នេះ បានបង្កឲ្យកម្ពុជាជួបប្រទះនូវបញ្ហាខ្វះភ្លើងអគ្គិសនីប្រើប្រាស់យ៉ាងខ្លាំង ដែលជាហេតុធ្វើឲ្យផ្ទែកជាច្រើននៅក្នុងទីក្រុងភ្នំពេញ និងនៅតាមបណ្តាខេត្តត្រូវបានកាត់ផ្តាច់ទៅតាមវេនក្នុងអំឡុងរដូវប្រាំងកន្លងទៅថ្មីៗនេះ។ កង្វះខាតភ្លើងអគ្គិសនីនេះ ត្រូវបានគេមើលឃើញថា ដោយសារកម្ពុជាពឹងផ្អែកមួយផ្នែកធំទៅលើប្រតិបត្តិការនៃទំនប់វារីអគ្គិសនីដែលពឹងផ្អែកទៅលើរបបទឹកពីផ្នែកខាងលើនៃទន្លេ ឬ ដៃទន្លេមេគង្គ និងរបបទឹកភ្លៀងទៀងទាត់ ដើម្បីផលិតថាមពលអគ្គិសនី។ តាមរយៈបទពិសោធន៍នេះ កម្ពុជាត្រូវគិតគូរអំពីជម្រើសនានា ដែលមានផលប៉ះពាល់បរិស្ថាន និងសង្គមតិចតួចក្នុងការផលិតថាមពល ដើម្បីកាត់បន្ថយការពឹងផ្អែកខ្លាំងទៅលើទំនប់វារីអគ្គិសនី។

## សម្រាប់ព័ត៌មានបន្ថែម សូមទំនាក់ទំនង

លោក ហុក ម៉េងហ៊ាន់ ប្រធានកម្មវិធីបរិស្ថាន
និងកសិកម្ម វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា
ទូរស័ព្ទ (៨៥៥ )១២ ៥០៥ ៥៦០
អ៊ីម៉ែល menghoin@ngoforum.org.kh

[4] Cambodia National Strategic Development Plan 2019-2023, page 336-337